**ធម្មទេសនារបស់លោកអភិបាល អូលីវីយេ**
**អភិបូជាជាមួយអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង**
**ចោមចៅ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៩**
**គ្រីស្តបរិស័ទជាប្រជារាស្ត្រនៃសេចក្តីសង្ឃឹម**

**អត្ថបទទី១៖ ធីម៉ូថេ ទី១ ១,១២-១៧**
ទោះបីពីដើមខ្ញុំធ្លាប់ប្រមាថ បៀតបៀន និងប្រព្រឹត្តអំពើឃោរឃៅក៏ដោយ ក៏ព្រះអង្គមានព្រះហឫទ័យមេត្តាករុណាដល់ខ្ញុំដែរ ព្រោះកាលណោះ ខ្ញុំគ្មានជំនឿ ហើយមិនយល់កិច្ចការដែលខ្ញុំប្រព្រឹត្ត។ ១ធម ១,១៣
**ដំណឹងល្អ៖ យ៉ូហាន ១៩,២៥-២៧**
ព្រះយេស៊ូឃើញមាតា ព្រមទាំងសាវ័កដែលព្រះអង្គស្រឡាញ់នោះឈរនៅជិត ទ្រង់មានព្រះបន្ទូលទៅមាតាថា៖ «អ្នកអើយ! នេះហើយកូនរបស់អ្នក»។ យហ ១៩,២៦

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះជាឱកាសមួយ សម្រាប់សរុបដំណើរនៃអដ្ឋិធាតុរបស់ សន្ត លូវីស និង សន្តី ហ្សឺលី ម៉ាតាំង នៅលើទឹកដីប្រទេសកម្ពុជា និងដើម្បីនឹកឃើញអ្វីដែលយើងបានទទួលពីគ្រួសារដ៏វិសុទ្ធនេះ។ ថ្ងៃនេះ យើងគោរពព្រះនាងម៉ារីដែលរងទុក្ខលំបាក ក្នុងគម្ពីរដែលយើងបានស្តាប់គឺមានលោកយ៉ូហាន និងព្រះនាងម៉ារីដែលនៅក្បែរឈើឆ្កាងរបស់ព្រះយេស៊ូ នៅពេលនោះព្រះយេស៊ូបានប្រទានព្រះនាងម៉ារីទៅលោកយ៉ូហាន និងប្រទានលោកយ៉ូហានទៅព្រះនាងម៉ារី។ លោកយ៉ូហាន ជានិមិត្តរូបរបស់យើងទាំងអស់ដែលជាប្រជារាស្ត្រព្រះជាម្ចាស់ ព្រះនាងម៉ារីជាមាតារបស់ព្រះជាម្ចាស់ នៅពេលនោះព្រះនាងម៉ារីទៅជាម្តាយរបស់ប្រជារាស្ត្រព្រះជាម្ចាស់ ព្រះនាងម៉ារីជាម្តាយរបស់ព្រះសហគមន៍ទាំងមូល។

ថ្ងៃនេះ ដែលយើងបញ្ចប់ការធ្វើដំណើរនៃអដ្ឋិធាតុរបស់ សន្ត លូវីស និង សន្តី ហ្សឺលី ម៉ាតាំង ដែលជាគ្រួសារដ៏វិសុទ្ធមួយ ជាឱកាសមួយដើម្បីនឹកឃើញ **តើសម្រាប់យើងនៅក្នុងប្រទេសកម្ពុជា យើងបានទទួលផ្លែអ្វីខ្លះ?** ក្នុងរយៈពេលពីរបីសប្តាហ៍ដែលបានធ្វើដំណើរជាមួយអដ្ឋិធាតុនេះ ដូចជាបានចូលរួមនៅក្នុងជីវិតជិតស្និទ្ធជាមួយក្រុមគ្រួសារសន្ត លូវីស និងសន្តី ហ្សឺលី ម៉ាតាំង ដែលមានកូនប្រាំនាក់នៅលើផែនដី និងកូនបួននាក់ទៀតបានទទួលមរណភាព។ ខ្ញុំបាននឹកឃើញពិតមែន ក្រុមគ្រួសារសំខាន់សម្រាប់សង្គមមួយ ពីដើមរៀងមកសម្រាប់ប្រទេសកម្ពុជា ក្រុមគ្រួសារសំខាន់ណាស់ ជាមូលដ្ឋានគ្រឹះនៃសង្គមតែម្តង។ ពេលយើងនិយាយអំពីគ្រួសារ គឺយើងគិតអំពីឪពុកម្តាយ អំពីមីងពូ អំពីយាយតា អំពីកូនចៅ ដូច្នេះគ្រួសារគឺធំណាស់ តាមភូមិ

នីមួយៗនៅពេលមានគ្រួសារមួយដែលបែកគ្នាពីឪពុកម្ដាយ តាមពិតគេមិនទៅនៅឆ្ងាយប៉ុន្មានទេ គឺគេបានសាងសង់ផ្ទះមួយនៅជិតឪពុកម្ដាយ ដូច្នេះភូមិនីមួយៗគឺជាមហាគ្រួសារមួយ។

នៅពេលប៉ុលពត ចូលទីក្រុងភ្នំពេញសកម្មភាពទីមួយគឺបណ្ដេញប្រជាជនពីទីក្រុងភ្នំពេញចេញទៅជនបទ ប៉ុន្តែនៅជនបទក៏មានការបាក់បែកគ្នាដែរ មានន័យថាគ្រួសារបានបាក់បែកគ្នា។ គ្រួសារដ៏សុខសាន្ត គឺណែនាំឲ្យគ្រួសារមានសេចក្ដីសុខ គ្រួសាររឹងមាំណែនាំឲ្យសង្គមរឹងមាំ ដូច្នេះនៅសម័យនោះ ពេលគេណែនាំឲ្យគ្រួសារបាក់បែកគ្នាសង្គមលែងរឹងមាំអស់ហើយ។ ដោយសារគ្រួសារមួយមានបងប្អូនខ្លះនៅទីនេះ មានឪពុកនៅទីនោះ ដូច្នេះអ្វីដែលណែនាំឲ្យសង្គមចូលគ្នាដើម្បីរឹងមាំបានបាក់បែកគ្នាអស់ហើយ នេះជាអ្វីដែលប៉ុលពតបានធ្វើ។ ប៉ុលពតបានបង្កើតគ្រួសារថ្មី គឺមិនមែនរបៀបដែលទីពឹងលើសេចក្ដីស្រឡាញ់ ដោយសារការរៀបអាពាហ៍ពិពាហ៍នៅក្នុងសម័យនោះ គឺគេបានប្រមូលបុរសស្ត្រីម្ដងៗមានជាច្រើនគូដើម្បីរៀបការដោយបង្ខំ ទាំងមិនដែលស្គាល់គ្នា មិនដែលស្រឡាញ់គ្នា។ គេបានបង្កើតគ្រួសារថ្មីដែលគ្មានសេចក្ដីសុខ ដោយទីពឹងលើអង្គការមួយតែប៉ុណ្ណឹង មិនមែនជាគ្រួសារដែលរស់នៅក្នុងសេចក្ដីសុខ និងភាពកក់ក្ដៅ ដែលចេះយល់ចិត្តគ្នា ចេះស្រឡាញ់គ្នាសោះ។

ក្រោយពីសម័យប៉ុលពត យើងរស់នៅក្រោមការដឹកនាំពីប្រទេសវៀតណាម បន្ទាប់មករស់នៅជាមួយអ៊ុនតាក់ និងអង្គការដែលមកពីប្រទេសនានា រហូតដល់ឆ្នាំ១៩៩៣ ដែលមានការបោះឆ្នោតដោយសេរីប្រទេសកម្ពុជាបានចាប់ផ្ដើមសាងសង់សារជាថ្មី។ សព្វថ្ងៃនៅប្រទេសកម្ពុជាយើងមានយុវជនយុវនារីច្រើន ដោយសារ៦០%នៃប្រជាជនមានអាយុក្រោម២៥ឆ្នាំ។ ដូច្នេះសុទ្ធតែជាយុវជនយុវនារីដែលកំពុងគិត **តើអនាគតខ្ញុំគឺធ្វើអ្វី?** អនាគតខ្ញុំទៅជាម្ដាយ ទៅជាឪពុក ទៅជាប្ដី ទៅជាប្រពន្ធ គឺយើងបង្កើតគ្រួសារ។ ដើម្បីបង្កើតគ្រួសារ យើងត្រូវការមានគំរូ យុវជនយុវនារីសព្វថ្ងៃគេពិបាកទទួលគំរូពីឪពុកម្ដាយ ដោយសារឪពុកម្ដាយបានរស់នៅក្នុងសម័យទុក្ខលំបាកនៅក្នុងការតស៊ូពីមួយថ្ងៃទៅមួយថ្ងៃ។ យុវជនយុវនារីមួយចំនួនទៀត មកពីគ្រួសារដែលមានកូនច្រើន សង្គមសព្វថ្ងៃមិនចង់ឲ្យយើងមានកូនច្រើនទេ ដោយសារគេមើលតាមប្រទេសអភិវឌ្ឍន៍មួយចំនួនដូចជាសិង្ហបុរី កូរ៉េ ជប៉ុន តាមរយៈប្រព័ន្ធផ្សព្វផ្សាយនានាដែលគេឃើញមានកូនច្រើនបំផុតពីរនាក់តែប៉ុណ្ណឹង។ ហេតុនេះហើយ សម្រាប់យុវជនយុវនារីសព្វថ្ងៃនេះជាសំណួរមួយយ៉ាងធំគឺ **តើខ្ញុំបង្កើតគ្រួសារដូចម្ដេចបាន? របៀបណា? យកគំរូពីណា?** ដោយសារការបន្តវប្បធម៌ ទាំងសាសនា ទាំងគ្រួសារ ទាំងការរស់នៅតាមប្រពៃណី ដូចជាដាច់ច្រើននៅក្នុងប្រទេសកម្ពុជា ដូច្នេះគេបានទទួលយកវប្បធម៌ថ្មីមកពីប្រទេសនានា ដោយសារយើងរស់នៅក្នុងពិភពលោកមួយយ៉ាងធំ យើងមើលនៅក្នុងទូរស័ព្ទ យើងចូលនៅក្នុងប្រទេសនីមួយៗធ្វើឲ្យយើងចង់ធ្វើដូចគេ។

សព្វថ្ងៃ ចង់បង្កើតគ្រួសារដែលជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំនៃសង្គម ពិបាកណាស់ ជាពិសេសនៅក្នុងបរិយាកាសនៅទីក្រុង និងភាពក្រីក្រ។ ប្រជាជនកម្ពុជាមួយចំនួនធំធ្វើការនៅប្រទេសថៃ ប្រទេសកូរ៉េ ប្រទេសសិង្ហបុរី ប្រទេសម៉ាឡេស៊ី និងប្រទេសមួយចំនួនទៀត ដែលពួកគេសុទ្ធតែជាវ័យដែលត្រូវបង្កើតគ្រួសារ។ មានខ្លះគេបានបង្កើតគ្រួសារហើយ គេទៅធ្វើការចោលកូនឲ្យនៅជាមួយយាយតា និងមួយចំនួនទៀតបានបោះបង់កូនចោល សព្វថ្ងៃបងស្រីមេត្តាករុណានៅផ្លូវមុន្នីវង្ស បានទទួលកូនក្មេងជាច្រើនដែលឪពុកម្តាយបោះបង់ចោល ដោយសារគេទៅឆ្ងាយ គេគ្មានសមត្ថភាព គេមិនចង់ចិញ្ចឹម។ យើងមានកូនក្មេងច្រើន ដែលរស់នៅជាមួយយាយតាចាស់ៗ ជាមួយមីងពូដែលមិនមែនជាឪពុកម្តាយបង្កើត គេបានជួបឪពុម្តាយគេមួយឆ្នាំម្តង ដូច្នេះកូនក្មេងនេះខ្វះសេចក្តីសុខនិងភាពកក់ក្តៅពីឪពុកម្តាយ។ កូនក្មេងមួយចំនួនទៀត ឪពុកម្តាយបានស្លាប់ដោយសារជំងឺនិងមូលហេតុនានា ដែលណែនាំឲ្យគេឯកោ នេះជាសង្គមរបស់យើងសព្វថ្ងៃ។

នៅពេលយើងបានទទួលអដ្ឋិធាតុរបស់សន្ត លូវីស និងសន្តី ហ្សេលី ម៉ាតាំង ដែលជាគ្រួសារដ៏វិសុទ្ធ នៅពេលយើងបានធ្វើដំណើរជាមួយ យើងអាចដាក់ចំណងជើងនៃដំណើរតាមកន្លែងនីមួយៗដូចជា៖

- ✓ គ្រួសារដ៏វិសុទ្ធ ប្តីប្រពន្ធដ៏វិសុទ្ធ
- ✓ ប្តីប្រពន្ធដែលបង្កើតគ្រួសារទំនើប ដែលមានអត្ថន័យសម្រាប់សង្គមបច្ចុប្បន្ននេះ
- ✓ ឪពុកម្តាយដែលអប់រំណែនាំកូនឲ្យកូនស្គាល់ស្ថានបរមសុខ និងជីវិតជាមួយព្រះជាម្ចាស់
- ✓ គ្រួសារដែលបានយកព្រះកាយព្រះគ្រីស្តជាអាទិភាពនៅក្នុងជីវិតផ្ទាល់ខ្លួន
- ✓ គ្រួសារដែលទទួលស្គាល់ថាព្រះជាម្ចាស់ជាព្រះបិតាដែលស្រឡាញ់យើងបំផុត
- ✓ គ្រួសារដែលរស់នៅនៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់ ដោយទុកចិត្តលើព្រះជាម្ចាស់ ដោយជឿថាព្រះជាម្ចាស់ចិញ្ចឹមយើងគ្រប់ពេលវេលា
- ✓ គ្រួសារដ៏វិសុទ្ធដែលបានទទួលការត្រាស់ហៅរួមជាមួយអ្នកម្តាយតេរេសា ជាមួយសន្តសិលាដែលបានកែប្រែចិត្តគំនិត ដើម្បីរស់នៅក្នុងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងជាពិសេសផ្តល់សក្ខីភាពយ៉ាងជាក់ស្តែងនៅក្នុងជីវិត
- ✓ សម្រាប់គ្រួសារនេះ ព្រះនាងម៉ារីសំខាន់ណាស់ ព្រោះព្រះនាងម៉ារីជាម្តាយដែលបានថែរក្សានិងស្រឡាញ់គ្រួសារនេះនឹងស្រឡាញ់កូន ដែលបានក្លាយជាកុមារកំព្រានៅពេលម្តាយស្លាប់

- ✓ គ្រួសារដែលបានតស៊ូនិងលះបង់ចោល ដើម្បីរស់នៅក្នុងសេចក្តីសុខ សុខចិត្តលីឈើឆ្កាង លះបង់ចោលដើម្បីទទួលបានជីវិតរួមជាមួយព្រះជាម្ចាស់
- ✓ គ្រួសារដែលប្រកាសដំណឹងល្អយ៉ាងជាក់ស្តែង ជាគ្រួសារគ្រីស្តទូត។

ដូច្នេះពេលយើងមើលនេះអស់ហើយ យើងអាចរកឃើញចំណុចយ៉ាងសំខាន់ ដើម្បីណែនាំឲ្យយុវជនយុវនារី និងគ្រួសារសព្វថ្ងៃ នឹកឃើញធ្វើយ៉ាងណាឲ្យជីវិតរបស់យើងអាចបង្កើតគ្រួសារដ៏សុខសាន្ត។ ទោះបីគ្រួសារនេះបានរស់នៅ ១២០ឆ្នាំមុន យើងដឹងថាជាមូលដ្ឋានសម្រាប់គ្រួសារទាំងអស់ យើងឆ្លងសតវត្សរ៍យើងឆ្លងទ្វីប ដូច្នេះ**តើមានអត្ថន័យយ៉ាងណាសម្រាប់យើងដែលនៅប្រទេសកម្ពុជាដែលរស់នៅក្នុងឆ្នាំ២០១៩?** ពោរពេញដោយអត្ថន័យដោយសារៈ

ទីមួយ **គេបានស្រឡាញ់គ្នាទៅវិញទៅមក** សេចក្តីស្រឡាញ់ដែលគេមានពីថ្ងៃដំបូងណែនាំឲ្យគេរៀបការជាមួយគ្នា រស់នៅជាមួយគ្នា ដោយបង្ហាញសញ្ញានៃសេចក្តីស្រឡាញ់អស់មួយជីវិតរបស់គេ។ បងប្អូនដែលបានចូលរួមនៅភ្នំពេញថ្មីក្នុងទិវាគ្រួសារ ខ្ញុំបានប្រមូល១៥០គូពេញមួយថ្ងៃ ពេលរសៀលខ្ញុំបានឲ្យស្អុរស្វកូឡាមួយគ្រាប់ទៅប្រពន្ធ និងឲ្យផ្កាកូលាបមួយទងទៅប្តី ក្រោយមកខ្ញុំថាដល់ពេលវេលាជូនគ្នាទៅវិញទៅមក ទោះបីយើងបានរៀបអាពាហ៍ពិពាហ៍១០ឆ្នាំ ២០ឆ្នាំ ៣០ឆ្នាំ ៥០ឆ្នាំហើយ ដើម្បីបង្ហាញសេចក្តីស្រឡាញ់រវាងគ្នានឹងគ្នា។ នេះជាសេចក្តីស្រឡាញ់ដែលយើងបន្តចិញ្ចឹមពីមួយឆ្នាំទៅមួយឆ្នាំ សេចក្តីស្រឡាញ់រវាងប្តីនិងប្រពន្ធ។

ទីពីរ **បង្កើតបរិយាកាសនៃសេចក្តីស្រឡាញ់នៅក្នុងក្រុមគ្រួសារ** ដោយទទួលជីវិត ទទួលកូន ឥតមានគម្រោងការយកកូនមួយឬកូនពីរ។ នៅក្នុងសង្គមទំនើប ភាគច្រើនមានកូនមួយឬពីរនាក់ ប៉ុន្តែសម្រាប់យើងព្រះជាម្ចាស់ឲ្យកូនប៉ុន្មានយើងទទួលប៉ុណ្ណឹង ព្រោះនេះជាជីវិតដែលព្រះជាម្ចាស់ប្រទានឲ្យយើង។

ទីបី **ឲ្យយើងអប់រំ ថែរក្សា ស្រឡាញ់កូន និងក្រុមគ្រួសារ** ដូចហ្សេលី និងល្វីស អប់រំកូនស្រឡាញ់កូន។ ហ្សេលី គាត់មានបទពិសោធន៍ពិបាកនៅក្នុងជីវិតកុមារភាពរបស់គាត់ ម្តាយគាត់មិនស្រឡាញ់គាត់ មិនចូលចិត្តគាត់ មិនថែរក្សាគាត់សោះ ប៉ុន្តែនៅពេលគាត់មានគ្រួសារគាត់មិនចង់បន្តបទពិសោធន៍អាក្រក់នេះដល់កូនៗរបស់គាត់ឡើយ។ គាត់បានយកចិត្តទុកដាក់អស់សមត្ថភាពដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់កូនៗ និងបង្កើតគ្រួសារដ៏សុខសាន្តមួយដោយទីពឹងលើព្រះជាម្ចាស់។

ទីបួន **បង្កើតគ្រួសារដ៏សុខសាន្ត ដោយទីពឹងលើព្រះជាម្ចាស់** យកព្រះជាម្ចាស់ជាអាទិភាព គេភ្ញាក់ពីម៉ោងប្រាំព្រឹក ដើម្បីអប់រំកូននិទានរឿងអំពីព្រះយេស៊ូ ចូលអភិបូជាជារៀងរាល់ថ្ងៃ ពេល

ល្ងាចអធិដ្ឋានជាមួយគ្នា មួយថ្ងៃៗគេនឹកឃើញព្រះជាម្ចាស់។ នៅក្នុងបន្ទប់បងគេ មានរូបព្រះនាងម៉ារីដែលបានញញឹមយ៉ាងស្អាតដល់តេរេសា និងព្យាបាលតេរេសា ជារៀងរាល់ថ្ងៃគេចូលនៅក្នុងបន្ទប់នោះដើម្បីនិយាយជាមួយព្រះនាងម៉ារី។ ដូចបងស្រីមេត្តាករុណានៅទីនេះ គាត់បានដាក់បន្ទប់អធិដ្ឋាននៅជាប់ផ្លូវចេញចូល ដើម្បីពេលចេញចូលម្តងជម្រាបសួរព្រះយេស៊ូ ជម្រាបសួរព្រះនាងម៉ារីម្តង។ យើងមិនសូត្រផ្តាំពីព្រឹកដល់យប់ ប៉ុន្តែយើងដឹងថាព្រះជាម្ចាស់ជាអាទិភាព ពេលយើងដឹងដូចនេះយើងមានកម្លាំងពីក្នុងចិត្តពិសេសថែមទៀត ដើម្បីទៅមុខនៅក្នុងជីវិតរបស់យើង។

ទីប្រាំ **គ្រួសារនេះជាគ្រួសារដែលបើកទ្វារ** មិនមែនជាគ្រួសារចង្អៀតចង្អល់ អាត្មានិយមដែលមិនចេះមើលអ្នកដទៃ។ គេបានយកព្រះយេស៊ូនៅលើឈើឆ្កាង ដូចអ្នកម្តាយតេរេសានៅពេលគាត់ឃើញព្រះយេស៊ូស្រេក មានន័យថាស្រេកទឹក ស្រេកសេចក្តីស្រឡាញ់ នេះជាអ្នកក្រីក្រ ជាអ្នកដែលគ្មានទីពឹងគ្មានសេចក្តីសង្ឃឹម ដែលបានទន្ទឹងរង់ចាំព្រះយេស៊ូដើម្បីលើកទឹកចិត្តគេ និងឆ្លើយតបសេចក្តីត្រូវការរបស់គេ។ គ្រួសារនេះ រៀងរាល់ថ្ងៃចន្ទគាត់បើកទ្វារដើម្បីឲ្យអ្នកក្រីក្រ អ្នកជំងឺចូលផ្ទះគាត់ គាត់បាននឹកឃើញអ្នកក្រីក្រ អ្នកដែលគ្មានទីពឹង អ្នកដែលវង្វេងផ្លូវ អ្នកដែលអស់សង្ឃឹម គាត់បានលើកទឹកចិត្តដោយអធិដ្ឋានផង និងបង្កើតទំនាក់ទំនងផង។

ទីប្រាំមួយ **ជាគ្រួសារដែលចេះភ្ជាប់គ្នាជាផ្លូងតែមួយនៅពេលមានទុក្ខលំបាក** គ្រួសារនីមួយៗមានទុក្ខលំបាកដោយបញ្ហានានា ដូចជាអំពើហិង្សា គ្រឿងញៀន ភាពក្រីក្រ...។ យើងមានទុក្ខលំបាកច្រើន ប៉ុន្តែឲ្យយើងផ្ញើទុក្ខលំបាកនេះទៅលើព្រះជាម្ចាស់នេះជាកម្លាំងមួយ ពេលយើងឥតមានជំនឿយើងធ្វើដូចម្តេចដើម្បីទៅមុខ ក្នុងជីវិតដែលយើងបានផ្ញើទៅលើព្រះជាម្ចាស់។ សម្រាប់យើងជាគ្រីស្តបរិស័ទ ជំនឿរបស់យើងជាកម្លាំងមួយយ៉ាងពិសេសដែលណែនាំឲ្យយើងចេះមើលឃើញការអស្ចារ្យរបស់ព្រះជាម្ចាស់ចំពោះយើង និងណែនាំឲ្យយើងអាចតស៊ូនៅក្នុងទុក្ខលំបាករបស់យើង។ ពេលយើងទទួលអគ្គសញ្ញាអាពាហ៍ពិពាហ៍ យើងបានសន្យាថាយើងភ្ជាប់គ្នាអស់មួយជីវិតទាំងគ្រាមានអំណរសប្បាយទាំងគ្រាមានទុក្ខលំបាក នេះជាជំនឿរបស់យើង។ យើងមិនមែនជាប្តីប្រពន្ធនៅតែពេលយើងសប្បាយចិត្ត ប៉ុន្តែនៅក្នុងពេលមានការពិបាកដែរ យើងជាគ្រួសារសុខសាន្តមិនមែនតែពេលយើងសប្បាយចិត្ត តែនៅក្នុងពេលយើងពិបាកចិត្តដែរ។

គ្រួសារនេះបានឆ្លងផុត នៅពេល ហ្សេលី មានជំងឺមហារីកសុដន់ដោយដឹងថាគាត់មានពេលតែ៦ខែដើម្បីរស់នៅ គាត់បានធ្វើដំណើរឆ្ងាយទៅឡូង គាត់អធិដ្ឋានដោយដឹងថាគាត់មិនអាចជាបានទេ ប៉ុន្តែគាត់ជឿថាការធ្វើដំណើររបស់គាត់ជោគជ័យណាស់ ដោយសារនៅពេល

នោះគាត់បានទុកចិត្តលើព្រះនាងម៉ារី ដោយផ្ញើកូនៗនិងប្ដីគាត់ទៅព្រះនាងម៉ារី ដោយយកព្រះនាងម៉ារីទៅជាម្ដាយរបស់កូនគាត់។ នេះជាការអស្ចារ្យមួយនៅក្នុងទុក្ខលំបាក មុនស្លាប់គាត់មានសេចក្ដីសុខដោយសារជំនឿរបស់គាត់ ណែនាំឲ្យគាត់យល់ថាព្រះនាងម៉ារីជាម្ដាយរបស់កូនគាត់ពិតមែន។

មុនពេល លូវីស ស្លាប់គាត់វង្វេងស្មារតីគាត់បាននិយាយទៅកូនស្រីដែលកំពុងព្រួយបារម្ភអំពីគាត់ថា "**កុំព្រួយបារម្ភ ដោយសារប៉ាជាមិត្តសម្លាញ់របស់ព្រះជាម្ចាស់**"។ យើងអធិដ្ឋាន សម្រាប់គ្រួសារទាំងអស់នៅប្រទេសកម្ពុជា តាមរយៈជីវិតរបស់យើងជាគ្រួសារកាតូលិកអាចទៅជាគ្រួសារដែលប្រកាសដំណឹងល្អ អាចរកឃើញគំរូនៅក្នុងគ្រួសារដ៏វិសុទ្ធនេះ ដើម្បីមានគុណធម៌ ដើម្បីមានរបៀប ដើម្បីមានកម្លាំង ដើម្បីកសាងជីវិតដ៏សុខសាន្ត ដើម្បីកសាងទាំងព្រះសហគមន៍ទាំងសង្គមនៅថ្ងៃអនាគត។ យើងអរព្រះគុណព្រះជាម្ចាស់ នៅពេលយើងគោរពព្រះនាងម៉ារីភ្ជាប់ជាមួយទុក្ខលំបាក ព្រះនាងម៉ារីដែលណែនាំឲ្យយើងរកឃើញសេចក្ដីសុខ ទោះបីមានទុក្ខលំបាកក៏ដោយយើងពោរពេញដោយសេចក្ដីសង្ឃឹម ដោយសារគ្រីស្តបរិស័ទជាប្រជារាស្ត្រនៃសេចក្ដីសង្ឃឹម។ អាម៉ែន៕